# ក្រឹត្យវិន័យមាស

ឯកសារថ្នាក់សិក្ខាសាលាសម្រាប់ព្រះគម្ពីរសញ្ញាថ្មី

| សេចក្ដីយោង | គុណលក្ខណៈ |
|---|---|
| **ម៉ាថាយ ៥:៣; នីហ្វៃ ទី៣ ១២:៣** | **មានសេចក្ដីកំសត់ខាងឯវិញ្ញាណ ។** ភាពរាបសា ឬ « ការទទួលស្គាល់ដោយដឹងគុណចំពោះការពឹងផ្អែករបស់យើងទៅលើព្រះអម្ចាស់—ដើម្បីយល់ថា យើងត្រូវការជំនួយពីទ្រង់ជានិច្ច ។ ការបន្ទាបខ្លួនគឺជាការទទួលស្គាល់ថា ទេពកោសល្យ និងសមត្ថភាពរបស់យើងគឺជាអំណោយមកពីព្រះ » ( ប្រធានបទដំណឹងល្អ « ការបន្ទាបខ្លួន » គេហទំព័រtopics.ChurchofJesusChrist.org ) ។ |
| **ម៉ាថាយ ៥:៤** | **យំសោក ។** ទទួលអារម្មណ៍ និងបង្ហាញពីទុក្ខព្រួយដោយសាររឿងអ្វីមួយ ។ មនុស្សម្នាក់អាចយំសោកដោយសារការសោកល្បងនៃជីវិតរមែងស្លាប់ ដែលពួកគេ និងអ្នកដទៃជួបប្រទះ ។ មនុស្សម្នាក់ក៏អាចយំសោកបាន ដោយសារតែភាពសោកសៅនៃអំពើបាបផងដែរ ។ |
| **ម៉ាថាយ ៥:៥** | **ស្លូតត្រង់ ។** ការធ្វើ « ‹ ជាអ្នកកោតខ្លាចដល់ព្រះ អ្នកមានចិត្តសុចរិត អ្នកមានចិត្តសុភាពរាបសា អ្នកចង់រៀន និងចេះអត់ធន់ចំពោះការរងទុក្ខ › [ សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ« ស្លូតបូត,ភាពស្លូតបូត » គេហទំព័រ scriptures.ChurchofJesusChrist.org ] ។ អ្នកដែលមានគុណលក្ខណៈនេះ មានឆន្ទៈធ្វើតាមព្រះយេស៊ូវគ្រីស្ទ ហើយអារម្មណ៍របស់ពួកគេគឺស្ងប់ស្ងៀម អធ្យាស្រ័យ មេត្តាធម៌ និងរាបទាប » ( អូលីសេស សូរ៉េស « ចូរមានចិត្តស្លូតបូត ហើយសុភាពរាបសា » *Ensign* ឬ *Liahona*ខែ វិច្ឆិកា ឆ្នាំ ២០១៣ ទំព័រ ៩ ) ។ |
| **ម៉ាថាយ ៥:៦; នីហ្វៃ ទី៣ ១២:៦** | **ស្រេកឃ្លាននូវសេចក្ដីសុចរិត ។** មានបំណងប្រាថ្នាចង់ដឹងដ៏ធំធេង និងធ្វើតាមព្រះហឫទ័យរបស់ព្រះ ។ |
| **ម៉ាថាយ ៥:៧** | **មានចិត្តមេត្តាករុណា ។** មាន « ចិត្តអាណិតអាសូរ គោរព អភ័យទោស សុភាពរាបសា និងអត់ធ្មត់ ទោះបីជាយើងដឹងពីកំហុសរបស់អ្នកដទៃក៏ដោយ » ( ប្រធានបទដំណឹងល្អ « សេចក្ដីមេត្តាករុណា » គេហទំព័រtopics.ChurchofJesusChrist.org ) ។ |
| **ម៉ាថាយ ៥:៨** | **មានចិត្តបរិសុទ្ធ ។** ត្រូវបានរាប់ក្នុងចំណោមអ្នកដែល « ស្រឡាញ់ព្រះអម្ចាស់ ដែលព្យាយាមដើរតាមទ្រង់ ហើយកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ដែលកំពុងប្រឹងរស់នៅក្នុងជីវិតប្រកបដោយគុណធម៌ ហើយស៊ូទ្រាំដោយចិត្តស្មោះត្រង់ដល់ទីបំផុត ។ អ្នកដែលមានចិត្តបរិសុទ្ធគឺជាអ្នកដែលគ្រប់គ្រងគំនិតរបស់ពួកគេ ដើម្បីរក្សាខ្លួនពួកគេឲ្យរួចផុតពីការស្រមើស្រមៃអសីលធម៌ និងអំពើអសីលធម៌ » ( ស៊ែលឌិន អេហ្វ ឆៃល « Words of Jesus: Chastity » *Ensign* ឬ *Liahona*ខែ មករា ឆ្នាំ ២០០៣ ទំព័រ ៤៤ ) ។ |
| **ម៉ាថាយ ៥:៩** | **អ្នកដែលផ្សះផ្សាគេ ។** « ដើម្បីជួយមនុស្សឲ្យរកឃើញមូលដ្ឋានរួម នៅពេលអ្នកដទៃកំពុងឃើញភាពខុសគ្នា » ( ហិនរី បី អាវរិង « Learning in the Priesthood » *Ensign* ឬ *Liahona*ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ៦៣ ) ។ |
| **ម៉ាថាយ ៥:១០–១២** | **ត្រូវគេបៀតបៀនដោយព្រោះសេចក្ដីសុចរិត ។** មានឆន្ទៈគោរព និងការពារព្រះយេស៊ូវគ្រីស្ទ និងការបង្រៀនរបស់ទ្រង់ សូម្បីតែនៅពេលដែលយើងត្រូវបានគេចំអក ឬធ្វើបាបចំពោះការធ្វើដូច្នោះក៏ដោយ ។ |

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ឆ្នាំ ២០២២ by Intellectual Reserve, Inc. All rights reserved. កំណែ ៖ ២/២១ ។ ការបកប្រែនៃ *The Beatitudes* ។
Cambodian ។ PD60012661 258. Printed in the United States of America.